CITY OF LONGBEACH

# PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ 2021
ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, 562.570.NEWS, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# សាលាក្រុងឡុងប៊ិច ផ្តល់មូលនិធិទ្រទ្រង់ គម្រោងសហគមន៍នានា ដើម្បីកែលំអលទ្ធភាពទទួលបាន អាហារសុខភាព ដែលមានថ្លៃសមរម្យ សម្រាប់អ្នកដែលពើបប្រទះនឹង បញ្ហាអសន្តិសុខស្បៀងអាហារ ដោយសារ COVID-19 ។

ឡុងប៊ិច, CA - នាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស ឡុងប៊ិច (នាយកដ្ឋានសុខាភិបាល) បានចុះកិច្ចសន្យា ជាមួយគ្រឹះស្ថាន ចំនួន 16 ដើម្បីផ្តល់សេវា និងការគាំទ្រ ពាក់ព័ន្ធនឹងអាហារូបត្ថម្ភ និង ផ្នែកស្បៀងអាហារ ជូនប្រជាពលរដ្ឋ ដែលពើបប្រទះនឹង បញ្ហាអសន្តិសុខស្បៀងអាហារ កម្រិតខ្ពស់ និង/ឬឧបសគ្គ ក្នុងការទទួលបានអាហារសុខភាព ដោយសារការឆ្លងរាតត្បាត COVID-19 ជាសាកលនេះ ។

ចៅហ្វាយក្រុង រ៉ូប៊ីត ហ្គាសៀ (Robert Garcia) «មិត្តភក្តិ និងអ្នកជិតខាងជាច្រើន របស់យើង កំពុងជួបប្រទះ បញ្ហាអសន្តិសុខស្បៀងអាហារ ដោយសារ COVID-19 ។» «គ្រឹះស្ថាននៅមូលដ្ឋានទាំងនេះ នឹងផ្តល់ជូន អាហារ និងធនធានអាហារូបត្ថម្ភ សំខាន់ៗ និងចាំបាច់នានា នៅទូទាំងសហគមន៍របស់យើង ។»

គ្រឹះស្ថាន មិនរកប្រាក់ចំណេញ, សហគ្រិន ខ្នាតមីក្រូ, គ្រឹះស្ថានសាសនា, និងស្ថាប័នអប់រំ ខាងក្រោមនេះ ទទួលបាន កិច្ចសន្យា បម្រើប្រតិបត្តិការ ។ ពួកគេទាំងអស់ ស្ថិតនៅក្នុងឡុងប៊ិច លើកលែងតែ មានបញ្ជាក់ ៖

- ក្លឹបក្មេងប្រុស និងក្មេងស្រី នៃក្រុងឡុងប៊ិច
- ក្រុមហ៊ុនរបាំ គម្រោងប្រុកខាស់ (ឡូស អ៊ែនជឺឡេស)
- សមាគមកម្ពុជា នៅអាមេរិក
- សេនត្រូ ចា (Centro CHA)
- សកម្មភាពផ្សព្វផ្សាយ សាសនាគ្រីស្ត (Christian Outreach in Action)
- ស៊ីធី ហ្វាប្រ៊ិក (City Fabrick)
- សុខភាព ប្រកបដោយសេចក្តីថ្លៃថ្នូ - មូលនិធិមជ្ឈមណ្ឌលវេជ្ជសាស្ត្រ ស៊ែន ម៉ារី (Dignity Health - St. Mary Medical Center Foundation)
- កសិដ្ឋាន ហ្គ្រូហ្សេរ៉ូ (Grow2Zero FARMS)
- សេវាគ្រួសារ & កុមារ ជ្វីស នៅឡុងប៊ិច ខោនធី អូរ៉េង ខាងលិច (Jewish Family & Children's Service of Long Beach & West Orange County)
- មជ្ឈមណ្ឌលសហគមន៍ ឡុងប៊ិច (Long Beach Community College)
- មជ្ឈមណ្ឌលបរិយាប័ន្នសេដ្ឋកិច្ច ឡុងប៊ិច (Long Beach Center for Economic Inclusion)
- សាកលវិទ្យាល័យរដ្ឋ ឡុងប៊ិច (Long Beach State University)
- ឡាវ ប៊ីយ៉ន លីមីត (Love Beyond Limits)

- សេវាអាហាកិច្ច ព្រីមម៉ល អាល់ឃេមី (Primal Alchemy Catering)
- សមាគម ហ្វេនតេ ឡាទីនណូ (Puente Latino Association)
- ក្រុមប្រឹក្សា សៅខូស អ៊ីនធីហ្វេស (South Coast Interfaith Council)

សកម្មភាព ដែលមានមូលនិធិគាំទ្រ ឱ្យដំណើរការ រហូតដល់ថ្ងៃទី 20 ខែមីនា ឆ្នាំ 2021 រួមមានព្រឹត្តិការណ៍ចែកអាហារ សម្រាប់ប្រជាពលរដ្ឋ នៅតាមភូមិស្ថានជួបការលំបាក ខណៈដែលសកម្មភាពផ្សេងៗ ទៀត ផ្តោតជាក់លាក់ លើប្រជាពលរដ្ឋ ដែលត្រូវបានកំណត់ជាស្រេច ថាជា «អាទិភាពខ្ពស់» ។ ដើម្បីស្វែងយល់ បន្ថែមទៀត អំពីគម្រោងអាហារូបត្ថម្ភសហគមន៍ ជាក់លាក់ និងការចុះឈ្មោះ ចូលសេវានានា, សូមចូលទៅ ទំព័រធនធាន និងជំនួយ COVID-19 របស់នាយកដ្ឋានសុខាភិបាល ។

កម្មវិធីទាំងនេះ ដំណើរការទៅបាន ដោយសារមូលនិធិ ក្រោមច្បាប់ ស្តីពីជំនួយវីរុសកូរ៉ូណា, ជំនួយសង្គ្រោះ និងសន្តិសុខសេដ្ឋកិច្ច ។ សាលាក្រុងទទួលបាន $40 លាន ជាមូលនិធិ ក្រោមច្បាប់ CARES ដើម្បីគាំទ្រដល់ការផ្តល់ជំនួយសង្គ្រោះ ព្រមទាំង ការស្តារ សហគមន៍ឡើងវិញ និងភាពរឹងមាំ ដែលក្នុងនោះ ក្រុមប្រឹក្សាក្រុងឡុងប៊ិច បានកំណត់យក $3 លាន សម្រាប់គាំទ្រគម្រោងនានា ដែលមានគោលដៅបង្កើនសន្តិសុខស្បៀងអាហារ រួមទាំង ទឹកប្រាក់ ជាង $500,000 គាំទ្រដល់គ្រឹះស្ថាននានា ដែលផ្តល់ ស្បៀងអាហារ និងសេវាពាក់ព័ន្ធនឹងអាហារូបត្ថម្ភ និងគាំទ្រដល់សហគមន៍ ដែលរងផលជះ ពីការឆ្លងរាតត្បាត COVID-19 ជាសាកល ។

សម្រាប់ព័ត៌មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់របស់សាលាក្រុងឡុងប៊ិច ក្នុងការរក្សាសុវត្ថិភាព របស់ប្រជាពលរដ្ឋរបស់យើង សូមចូលទៅ long-beach.gov/COVID19 ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។

# # #